អេភេសូរ៣:១-១៣

# ជំពូក ៣

*គោលដៅ ក្រុមជំនុំជាអាថ៌កំបាំង*
*ការបកស្រាយអាថ៌កំបាំងនៃក្រុមជំនុំ*
*អត្ថន័យនៃពាក្យអាថ៌កំបាំង*
*សេចក្ដីអធិស្ឋានទូលសូមចេស្ដា និងចំណេះ*

## ក្រុមជំនុំជាអាថ៌កំបាំង

ក្នុងសំបុត្រដែលលោកសរសេរទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ ជំពូក៣ជាជំពូកចុងក្រោយបង្អស់សាវ័កប៉ុលរៀបរាប់ពីគោលទ្ធិនៃក្រុមជំនុំ។ ទាក់ទងនឹងគោលទ្ធិរបស់ក្រុមជំនុំ ទីមួយ ក្រុមជំនុំជារូបកាយរបស់អង្គព្រះយេស៊ូវគ្រីស្ទ ទីពីរ ក្រុមជំនុំជាត្រសាលជំនុំ។ ឥឡូវ យើងនឹងសិក្សាពីគោលទ្ធិទីបីនៃក្រុមជំនុំ គឺក្រុមជំនុំជាអាថ៌កំបាំងរបស់ព្រះជាម្ចាស់។

តើអ្វីដែលជាអាថ៌កំបាំងរបស់ក្រុមជំនុំ? កន្លងមកមានការយល់ច្រឡំច្រើនណាស់ពីដំណើរអាថ៌កំបាំងនៃក្រុមជំនុំ។ ពាក្យថា "អាថ៌កំបាំង" នៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ មានលក្ខណៈខុសស្រឡះពីអត្ថន័យនៃពាក្យអាថ៌កំបាំង ដែលយើងធ្លាប់

ឮគេនិយាយក្នុងន័យធម្មតា។ ក្នុងន័យធម្មតា ពាក្យ "អាថ៌កំបាំង" មានន័យថា ហេតុការណ៍មួយបានកើតឡើង តែឥតមានអ្នកណាដឹងថា រឿងនោះកើតដោយសារអ្វី។ អាថ៌កំបាំងក្នុងព្រះបន្ទូលមានអត្ថន័យខុសទាំងស្រុងពីរឿងខាងលើ។ អាថ៌កំបាំងនៃក្រុមជំនុំគឺរឿងនោះកាលពីគ្រាមុននៅបិទមុខ តែឥឡូវនេះ ព្រះជាម្ចាស់បានបើកសម្តែងអោយយើងស្គាល់ហើយ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់មិនបានបើកសម្តែងថា មានក្រុមជំនុំទេ។ ប៉ុន្តែ ក្នុងគ្រាព្រះគម្ពីរសញ្ញាថ្មី ទើបយើងឃើញមានក្រុមជំនុំរបស់ព្រះជាម្ចាស់កើតឡើង។ បណ្ឌិតម៉ូហ្វែត អោយអត្ថន័យនៃពាក្យអាថ៌កំបាំងក្នុងព្រះបន្ទូលថា ជាសេចក្តីលាក់ទុករបស់ព្រះជាម្ចាស់។ ចំណែកបណ្ឌិតវ៉ើម៉ាវត៍ ហៅសេចក្តីអាថ៌កំបាំងក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា ជាសេចក្តីពិត។ សេចក្តីពិតនៅក្នុងព្រះបន្ទូលរបស់ព្រះ ជាសេចក្តីលាក់ទុកក្នុងគំនិតរបស់ព្រះជាម្ចាស់ សម្រាប់បើកសម្តែងអោយមនុស្សលោកស្គាល់ក្នុងគ្រាកំណត់។ បច្ចុប្បន្ននេះ ព្រះជាម្ចាស់បើកសម្តែងអោយយើងស្គាល់អាថ៌កំបាំងរបស់ទ្រង់ហើយ។ សាវ័កប៉ុលពន្យល់យើងជារឿយៗរួចមកហើយពីដំណើរអាថ៌កំបាំងនៅក្នុងគម្ពីរអេភេសូរជំពូក១។

នៅក្នុងផ្នត់គំនិតរបស់គ្រីស្ទបរិស័ទ មានការយល់ដឹងពីរយ៉ាងពីដំណើរអាថ៌កំបាំងនៃក្រុមជំនុំ។ ការយល់ដឹងទាំងពីរប្រភេទនោះ សុទ្ធតែមានលក្ខណៈជ្រុលនិយមដោយខ្លះប្រកាន់ឆ្វេងខ្លាំងពេក ខ្លះប្រកាន់ស្តាំខ្លាំងពេក។ អ្នកដែលប្រកាន់ស្តាំជ្រុលគេយល់ថា ក្រុមជំនុំរបស់ព្រះជាម្ចាស់ គឺជាសាសន៍អ៊ីស្រាអែល ក្នុងព្រះគម្ពីរសញ្ញាចាស់។ ក្រុមនេះប្រកាន់ផ្នត់គំនិតតាមទេវសាស្រ្តជាប់កិច្ចសន្យា។ គេប្រកាន់ថា កិច្ច

សន្យាទាំងឡាយ ដែលព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកអ័ប្រាហាំ ត្រូវបានសម្រេចដល់ក្រុមជំនុំរបស់ព្រះជាម្ចាស់សព្វថ្ងៃនេះដែរ។ ប៉ុន្តែ ជាក់ស្តែង ក្រុមនេះច្រើនប្រកាន់ថា គេទទួលតែព្រះពរព្រះជាម្ចាស់ប្រទានដល់លោកអ័ប្រាហាំទេ គេមិនព្រមទទួលសេចក្តីបណ្តាសា ដែលព្រះជាម្ចាស់ទម្លាក់មកលើសាសន៍អ៊ីស្រាអែល។ សូមចាំថា សាសន៍អ៊ីស្រាអែលទទួលទាំងព្រះពរ ទាំងសេចក្តីបណ្តាសា។

មួយទៀត ក្រុមដែលប្រកាន់ឆ្វេងជ្រុល គេប្រកាន់ថា សាវ័កប៉ុលតែមួយរូបគត់មានសិទ្ធិទទួលអាថ៌កំបាំងសម្រាប់ការបង្កើតក្រុមជំនុំរបស់ព្រះជាម្ចាស់។ ដោយសារហេតុនោះ គេមិនទទួលស្គាល់ថា ក្រុមជំនុំរបស់ព្រះជាម្ចាស់មានដើមកំណើតនៅថ្ងៃបុណ្យទីហាសិប។ គេយល់ថា ដើមកំណើតរបស់ក្រុមជំនុំចាប់ផ្តើមយូរក្រោយពីថ្ងៃបុណ្យទីហាសិប។ បញ្ហាដែលក្រុមនេះជួបប្រទះ គឺមិនយល់ស្របគ្នាពីថ្ងៃណាមួយរាប់ថាជាថ្ងៃកំណើតរបស់ក្រុមជំនុំ។ ខ្លះរាប់ថា ថ្ងៃនេះ ខ្លះរាប់ថាថ្ងៃនោះ។ ការរាប់យកថ្ងៃណាមួយមកធ្វើជាកំណើតរបស់ក្រុមជំនុំ ច្រើនទាក់ទងនឹងអំនួតខាងព្រលឹងវិញ្ញាណរបស់អ្នកដឹកនាំក្រុមនោះ។

ខ្ញុំចង់បញ្ជាក់ជំហររបស់ខ្ញុំពីអាថ៌កំបាំងនៃក្រុមជំនុំ។ ព្រះជាម្ចាស់មិនបានបើកសម្តែងអោយមានក្រុមជំនុំក្នុងគ្រាព្រះគម្ពីរសញ្ញាចាស់ទេ។ មិនតែប៉ុណ្ណោះ ព្រះជាម្ចាស់បានបើកសម្តែងអោយស្គាល់ពីសេចក្តីពិតនៃក្រុមជំនុំ មិនមែនសម្រាប់តែសាវ័កប៉ុលម្នាក់គត់តែប៉ុណ្ណោះដែរ។ ខ្ញុំប្រកាន់យ៉ាងតឹងរ៉ឹងថា ថ្ងៃកំណើតរបស់ក្រុមជំនុំ កើតនៅថ្ងៃបុណ្យទីហាសិប។ នៅថ្ងៃនេះឯង ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ត្រាស់

ហៅមនុស្សអោយចូលមកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាអង្គសង្គ្រោះ រួចហើយព្រះអង្គជ្រមុជគេដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ ដាក់ចូលទៅក្នុងរូបកាយរបស់ទ្រង់ហៅថាជាក្រុមជំនុំនៅលើផែនដីនេះ។ ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គបោះត្រាពួកអ្នកជឿទុកសម្រាប់ថ្វាយដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ នៅថ្ងៃដែលព្រះអង្គយាងមកលើកក្រុមជំនុំរបស់ព្រះអង្គ នៅក្រោមហាសោមនស្ស។ ថ្ងៃកំណើតរបស់ក្រុមជំនុំ ចាប់ផ្តើមនៅថ្ងៃបុណ្យទីហាសិប ដូចព្រះគម្ពីរកិច្ចការបានសម្តែងកន្លងមក។

## ការបកស្រាយអាថ៌កំបាំងនៃក្រុមជំនុំ

**[១]ហេតុនោះបានជាប៉ុលខ្ញុំ ជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ដែលខ្ញុំជាប់គុកនេះ ដើម្បីជាប្រយោជន៍ដល់អ្នករាល់គ្នា ជាពួកសាសន៍ដទៃ [២]គឺបើពិតណាស់ អ្នករាល់គ្នាបានឮនិយាយពីការត្រួតត្រារបស់ព្រះគុណនៃព្រះ ដែលបានប្រទានមកខ្ញុំសំរាប់អ្នករាល់គ្នាថា (អេភេសូរ៣:១-២)។**

នៅក្នុងខណៈដែលសាវ័កប៉ុល សរសេរសំបុត្រដូចយើងអានក្នុងខខាងលើ លោកស្ថិតនៅក្នុងទីឃុំឃាំងនាទីក្រុងរ៉ូម។ មូលហេតុដែលនាំអោយគេយកលោកទៅដាក់នៅក្នុងមន្ទីរឃុំឃាំង ពីព្រោះលោកបានផ្សាយដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវ

គ្រីស្ទ ដល់ពួកសាសន៍ដទៃ។ ដោយសារដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ សាសន៍ដទៃមានឯកសិទ្ធិដូចយើងបានរៀបរាប់ក្នុងជំពូក២កន្លងទៅ។ បុគ្គលគ្រប់រូបទោះបីជននោះជានរណាក្តី ពីដើមជាសាសន៍ដទៃ គ្មានទីសង្ឃឹម គ្មានព្រះ ឥឡូវនេះ មានឯកសិទ្ធិមានមុខមាត់ក្នុងអង្គព្រះគ្រីស្ទយេស៊ូវ។ ដោយមូលហេតុនេះហើយ បានជាសាវ័កប៉ុលចង់អធិស្ឋានអោយក្រុមជំនុំដែលជាសាសន៍ដទៃ។ ប៉ុន្តែ មុននឹងលោកអធិស្ឋាន លោកបានរៀបរាប់ពីអាថ៌កំបាំងនៃក្រុមជំនុំ។ លោកបានបរិយាយអាថ៌កំបាំងនេះចាប់ពី៖១-១៧ ក្នុងជំពូក៣។ នៅក្នុងបរិបទនេះទាំងមូល សាវ័កប៉ុលចាប់ផ្តើមដោយពាក្យថា "ហេតុនោះបានជាប៉ុលខ្ញុំ ជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ដែលខ្ញុំជាប់គុកនេះ ដើម្បីជាប្រយោជន៍ដល់អ្នករាល់គ្នា ជាពួកសាសន៍ដទៃ...ខ្ញុំលុតជង្គង់ នៅចំពោះព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា"។ នៅក្នុងអត្ថបទដើមជាភាសាក្រេកបរិបទពី៖១-១៤ សរសេរនៅក្នុងវង់ក្រចក។ មុននឹងលោកអធិស្ឋានដល់ក្រុមជំនុំជាសាសន៍ដទៃ លោកពន្យល់ពីអត្ថន័យនៃអាថ៌កំបាំងក្រុមជំនុំ។

សាវ័កប៉ុលមានប្រសាសន៍ក្នុង៖១ថា "ហេតុនោះ"។ ពាក្យនេះលោកចង់មានប្រសាសន៍ថា ព្រះជាម្ចាស់ប្រទានសេចក្តីសង្គ្រោះដល់យើងគ្រប់គ្នា ក្រោមការកាន់កាប់ត្រួតត្រានៃព្រះគុណរបស់ព្រះអង្គ។ ត្រង់នេះសាវ័កប៉ុលចង់បញ្ជាក់ថា ព្រះជាម្ចាស់បានត្រៀមលក្ខណៈគ្រប់បែបយ៉ាង ដើម្បីត្រាស់ហៅលោក រួចហើយបញ្ជូនលោកអោយនាំដំណឹងល្អទៅដល់សាសន៍ដទៃ។ បើយើងប្រៀបធៀបកិច្ចការរបស់សាវ័កប៉ុល ទៅនឹងកិច្ចការរបស់សាវ័កឯទៀត កិច្ចការសាវ័កប៉ុលមានលក្ខណៈវិសេសផង ពិសេសផង។

ក្នុងគម្ពីរកាឡាទី២:៧ សាវ័កប៉ុលមានប្រសាសន៍ថា "តែកាលគេបានឃើញថា ដំណឹងល្អសំរាប់ពួកមិនកាត់ស្បែក បានផ្ញើទុកនឹងខ្ញុំ ដូចជាដំណឹងល្អសំរាប់ពួកកាត់ស្បែក បានផ្ញើទុកនឹងលោកពេត្រុសដែរ"។ ដំណឹងល្អដែលសាវ័កប៉ុលនាំទៅដល់សាសន៍ដទៃ មានលក្ខណៈដូចជាដំណឹងល្អរបស់សាវ័កឯទៀតៗដែរ។ ប៉ុន្តែ អ្នកទទួលដំណឹងល្អ មានលក្ខណៈខុសគ្នា។ សាវ័កប៉ុលនាំដំណឹងល្អដល់សាសន៍ដទៃ។ ដំណឹងល្អនោះមានលក្ខណៈដូចជាដំណឹងល្អដែលសាវ័កពេត្រុស ប្រកាសក្នុងគម្ពីរកិច្ចការ៤:១២ដែរ។ ខនេះចែងថា "ហើយគ្មានសេចក្ដីសង្គ្រោះ ដោយសារអ្នកណាទៀតសោះ ដ្បិតនៅក្រោមមេឃ គ្មាននាមឈ្មោះណាទៀតបានប្រទានមកមនុស្សលោក ឱ្យយើងរាល់គ្នាបានសង្គ្រោះនោះឡើយ"។ នៅពេលសាវ័កប៉ុលមានប្រសាសន៍ទៅកាន់អ្នកគ្រប់គ្រងមន្ទីរឃុំឃាំងនៅស្រុកភីលីព លោកមានប្រសាសន៍ថា "...ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារលោកផង" (កិច្ចការ១៦:៣១)។ សាវ័កពេត្រុស និងសាវ័កប៉ុលនាំដំណឹងល្អនៃសេចក្ដីសង្គ្រោះតែមួយប្រភេទ ប៉ុន្តែបណ្ដាជនដែលទទួលដំណឹងល្អមានពីរពួកខុសគ្នា។ សាវ័កពេត្រុសនាំដំណឹងល្អដល់សាសន៍យូដា ឯសាវ័កប៉ុលនាំដំណឹងល្អដល់សាសន៍ដទៃ។

ចាប់ពីគ្រាសាវ័កប៉ុលនាំដំណឹងល្អទៅដល់សាសន៍ដទៃ បរិយាកាសមានលក្ខណៈប្លែកពីបរិយាកាសដែលស្ថិតនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ កាលលោកប៉ុលមានតួនាទីជាអាចារ្យផារិស៊ីក្រោមបន្ទុកក្រឹត្យវិន័យ លោកមិនបានធ្វើដំណើរទៅផ្សាយដំណឹងដល់សាសន៍ដទៃទេ។ លោកមិនអាចធ្វើការនោះបាន ពីព្រោះលោកស្ថិតនៅ

ក្រោមបរិយាកាសដោយឡែកពីបរិយាកាសបច្ចុប្បន្ន។ បច្ចុប្បន្ននេះ សាវ័កប៉ុលជាបេសកជននាំដំណឹងល្អទៅដល់សាសន៍ដទៃ។ ត្រង់នេះមិនមែនមានន័យថា វិធីដែលព្រះជាម្ចាស់ប្រើសម្រាប់ផ្តល់សេចក្តីសង្គ្រោះដល់មនុស្សលោក មានលក្ខណៈខុសគ្នា គឺវិធីមួយសម្រាប់សាសន៍ដទៃ មួយទៀតសម្រាប់សាសន៍យូដាទេ។ មនុស្សគ្រប់រូបមិនអាចទទួលសេចក្តីសង្គ្រោះបានដោយសារការធ្វើតាមក្រឹត្យវិន័យឡើយ។ អ្នកដែលស្ថិតនៅក្រោមបន្ទុកក្រឹត្យវិន័យ បានទទួលសេចក្តីសង្គ្រោះដោយធ្វើយញ្ញបូជាថ្វាយដល់ព្រះជាម្ចាស់ ពេលគេដឹងថា គេបានប្រព្រឹត្តអំពើបាបណាមួយទាស់នឹងព្រះអង្គ។ យញ្ញបូជាទាំងអម្បាលមាណនោះ សុទ្ធតែចង្អុលសំដៅទៅចំអង្គព្រះគ្រីស្ទយេស៊ូវ។

ឥឡូវនេះ សាវ័កប៉ុលមានប្រសាសន៍ពីស្ថានភាពថ្មីមួយទៀតដែលកើតឡើងនៅពេលដែលដំណឹងល្អបានជ្រួតជ្រាបចូលទៅដល់សាសន៍ដទៃ។

**៣ "ទ្រង់បានធ្វើឱ្យខ្ញុំស្គាល់ការអាថ៌កំបាំង ដោយការបើកសំដែង ដូចជាខ្ញុំសរសេរយ៉ាងខ្លីពីកាលមុនដែរ ៤ កាលណាអ្នករាល់គ្នាមើលសំបុត្រនោះ នោះនឹងអាចយល់ពីចំណេះខ្ញុំ ខាងឯការអាថ៌កំបាំងរបស់ព្រះគ្រីស្ទបាន (អេភេសូរ៣:៣-៤)។**

"ដោយការបើកសំដែង"។ ដូចខ្ញុំបានជម្រាបខាងលើរួចមកហើយថា មានអ្នកប្រកាន់អាថ៌កំបាំងនៃក្រុមជំនុំពីរពួក។ មួយពួកប្រកាន់ថា ក្រុមជំនុំ គឺជាសាសន៍

អ៊ីស្រាអែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ឯអ្នកប្រកាន់ជ្រុលនិយមម្ខាងទៀត គេប្រកាន់ថា ព្រះជាម្ចាស់បើកសម្តែងអោយសាវ័កប៉ុលតែមួយរូបគត់ដឹងពីអាថ៌កំបាំងនៃក្រុមជំនុំ។ គម្ពីរអេភេសូរជំពូក៣:៥បញ្ជាក់អោយយើងដឹងច្បាស់ថា ព្រះជាម្ចាស់មិនមែនគ្រាន់តែបើកអោយសាវ័កប៉ុលដឹងពីអាថ៌កំបាំងនៃក្រុមជំនុំតែម្នាក់គត់ឯងប៉ុណ្ណោះទេ។ ព្រះអង្គបើកអោយពួកសាវ័ក និងហោរាបរិសុទ្ធឯទៀតស្គាល់ពីអាថ៌កំបាំងនៃក្រុមជំនុំ ដោយសារព្រះវិញ្ញាណបរិសុទ្ធដែរ។ ឯការបើកសម្តែងដែលសាវ័កប៉ុលមានប្រសាសន៍ក្នុង ខ៣នេះ គឺជាការបើកសម្តែង ដែលព្រះជាម្ចាស់បណ្តាលអោយសាវ័កប៉ុលស្គាល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាអង្គសង្គ្រោះ ពេលលោកកំពុងធ្វើដំណើរទៅធ្វើការបៀតបៀនដល់ក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ នៅពេលនោះព្រះអម្ចាស់យេស៊ូវគ្រីស្ទបើកសម្តែងថា ការបៀតបៀនដល់ពួកជំនុំព្រះអម្ចាស់យេស៊ូវគ្រីស្ទ មានន័យថាបៀតបៀនព្រះអម្ចាស់យេស៊ូវផ្ទាល់។ ក្រុមជំនុំជារូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ នៅពេលដែលលោកសុលធ្វើបាបក្រុមជំនុំ លោកយល់ពីអាថ៌កំបាំងថ្មីមួយនោះ។ ការធ្វើទុក្ខបុកម្នេញដល់ក្រុមជំនុំរបស់ព្រះជាម្ចាស់ ជាការធ្វើទុក្ខបុកម្នេញដល់អង្គព្រះគ្រីស្ទផ្ទាល់។ ក្រុមជំនុំចាប់កំណើតឡើងនៅថ្ងៃបុណ្យទីហាសិប។

ខ្ញុំបានជម្រាបរួចមកហើយថា "អាថ៌កំបាំង" ជាគំនិតលាក់ទុករបស់ព្រះជាម្ចាស់ បើសម្តែងអោយមនុស្សលោកស្គាល់តាមកាលកំណត់របស់ទ្រង់។ ឯគំនិតលាក់ទុកនេះទៀតសោត ព្រះជាម្ចាស់មិនបានបើកសម្តែងអោយមនុស្សលោកស្គាល់ក្នុងគ្រាព្រះគម្ពីរសញ្ញាចាស់ទេ។ ព្រះអង្គបើកសម្តែងអោយមនុស្សលោកស្គាល់ពីក្រុមជំនុំរបស់

ទ្រង់នៅក្នុងព្រះគម្ពីរសញ្ញាថ្មី។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូល ពាក្យអាថ៌កំបាំងមានប្រើដល់ទៅចំនួនម្ភៃប្រាំពីរដង។ ឯប្រភេទនៃអាថ៌កំបាំងវិញ មានដល់ទៅចំនួនដប់មួយមុខខុសៗគ្នា។ នៅក្នុងជំនាន់សាវ័កប៉ុលកំពុងពន្យល់ពីអាថ៌កំបាំងនៃក្រុមជំនុំ រាជការរ៉ូមមានអត្ថន័យនៃពាក្យអាថ៌កំបាំងរបស់គេដែរ។ ចំពោះសាសន៍រ៉ូម សាសនាគេជាអាថ៌កំបាំងដល់សាសនិក។ សាសនិកមិនចាំបាច់យល់ពីអាថ៌កំបាំងនៃសាសនារបស់ពួករ៉ូមទេ។ កាតព្វកិច្ចរបស់គេ គឺត្រូវជឿតាមមេដឹកនាំនយោបាយតែម្យ៉ាងប៉ុណ្ណោះ។ ចំពោះព្រះជាម្ចាស់វិញ ទ្រង់មិនមែនលាក់សេចក្ដីអាថ៌កំបាំងទុកដូចអ្នកដឹកនាំរាជការរ៉ូមទេ។ ព្រះអង្គបើកសម្ដែងអោយយើងស្គាល់ អាថ៌កំបាំងរបស់ព្រះអង្គដល់មនុស្សលោកតាមកាលកំណត់របស់ព្រះអង្គ។ សាវ័កប៉ុលមានប្រសាសន៍ថា "វរហើយខ្ញុំ បើខ្ញុំមិនបានផ្សាយដំណឹងល្អ"។ យើងគ្រប់រូបជាភ្នាក់ងារត្រូវនាំសេចក្ដីអាថ៌កំបាំងរបស់ព្រះជាម្ចាស់ប្រាប់ដល់មនុស្សលោក។ អាថ៌កំបាំងរបស់ព្រះជាម្ចាស់ យើងត្រូវនាំដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទចេញទៅដល់ទីបំផុតនៃផែនដី។ យើងមិនត្រូវលាក់ដំណឹងល្អទុកតែខ្លួនឯងទេ។ យើងចាំបាច់ត្រូវឡើងលើដំបូលផ្ទះស្រែកប្រកាសអោយអស់សម្លេងថែមទៀតផង។

សាវ័កប៉ុល ពន្យល់ពីអត្ថន័យនៃពាក្យអាថ៌កំបាំងនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ជារឿយៗកន្លងមកហើយ។ ក្នុងគម្ពីរអេភេសូរ១:៩ លោកមានប្រសាសន៍ថា "ព្រមទាំងសំដែង ឱ្យយើងរាល់គ្នាស្គាល់សេចក្ដីអាថ៌កំបាំង នៃព្រះហឫទ័យទ្រង់ តាមគំនិតដែលទ្រង់បានគិតសំរេច ក្នុងព្រះអង្គទ្រង់"។ ឯគម្ពីរអេភេសូរ២:១៤-១៥ លោក

បានពន្យល់ពីអត្ថន័យនៃសេចក្តីអាថ៌កំបាំងនេះដែរ។ សេចក្តីអាថ៌កំបាំងនោះគឺ ព្រះគ្រីស្ទទ្រង់រស់ពីសុគតឡើងវិញ ធ្វើជាសិរសានៃក្រុមជំនុំដែលមានទាំងសាសន៍យូដា និងសាសន៍ដទៃ។ អាថ៌កំបាំងបែបនេះ មិនដែលមានអ្នកណាដឹងនៅក្នុងព្រះគម្ពីរសញ្ញាចាស់។ ក្នុងគម្ពីររ៉ូម១៦:២៥សាវ័កប៉ុលបញ្ជាក់ថា "រីឯព្រះ ដែលអាចនឹងតាំងអ្នករាល់គ្នាឱ្យខ្ជាប់ខ្ជួនតាមដំណឹងល្អខ្ញុំ នឹងតាមខ្លឹមនៃលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវនឹងសេចក្តីបើកសំដែង អំពីការអាថ៌កំបាំង ដែលបានលាក់ទុកនៅអស់ទាំងល្បរៀងមក"។ រីឯគម្ពីរកូល៉ុស១:២៦វិញ លោកមានប្រសាសន៍បន្ថែមទៀតថា "គឺជាសេចក្តីអាថ៌កំបាំងដែលលាក់ទុក តាំងពីអស់កល្បរៀងរាល់តែដំណតមក តែឥឡូវនេះ បានបើកសំដែងឱ្យពួកបរិសុទ្ធទ្រង់ស្គាល់"។

យើងចង់បញ្ជាក់ម្តងទៀតថា នៅក្នុងព្រះគម្ពីរសញ្ញាចាស់មិនមានក្រុមជំនុំរបស់ព្រះជាម្ចាស់ទេ។ បើមានជនណាហ៊ាននិយាយថា ក្រុមជំនុំរបស់ព្រះអង្គមានតាំងពីគ្រាព្រះគម្ពីរសញ្ញាចាស់ អ្នកនោះកំពុងតែអួតខ្លួនថា គេចេះជាងព្រះជាម្ចាស់ហើយ។ អាថ៌កំបាំងមានន័យថា ហេតុការណ៍ដែលព្រះជាម្ចាស់មិនទាន់បើកអោយយើងស្គាល់ក្នុងគ្រាព្រះគម្ពីរសញ្ញាចាស់។

## អត្ថន័យនៃពាក្យអាថ៌កំបាំង

**៥ជាការអាថ៌កំបាំងដែលកាលនៅអស់ទាំងគ្រាជាន់មុន មិនបាន**
**ប្រទានឱ្យពួកមនុស្សជាតិស្គាល់ ដូចជាបានសំដែងមកឱ្យពួកសាវក**
**នឹងពួកហោរាបរិសុទ្ធស្គាល់ ដោយសារព្រះវិញ្ញាណសព្វថ្ងៃនេះទេ**
**៦គឺដែលពួកសាសន៍ដទៃ បានត្រឡប់ជាអ្នកគ្រងមរដកជាមួយគ្នា**
**នឹងជារូបកាយជាមួយគ្នា ហើយជាអ្នកទទួលចំណែកនៃសេចក្តី**
**សន្យារបស់ទ្រង់ ជាមួយគ្នាក្នុងព្រះគ្រីស្ទដែរ ដោយសារដំណឹងល្អ**
**(អេភេសូរ៣:៥-៦)។**

ក្នុងអត្ថបទខាងលើ សាវ័កប៉ុលបញ្ជាក់ថា ព្រះជាម្ចាស់បើកសម្តែងអាថ៌កំបាំងអោយពួកហោរា និងពួកសាវ័កឯទៀតៗដឹងដែរ ស្តីពីអាថ៌កំបាំងនៃក្រុមជំនុំរបស់ព្រះអង្គ។

ពេលនេះលោកពន្យល់អោយបានច្បាស់ ពីអត្ថន័យនៃពាក្យអាថ៌កំបាំងក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់មិនមានក្រុមជំនុំទេ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងឃើញមានពាក្យដែលលោកប្រើថា ជាពួកសាវ័កនិងពួកហោរាបរិសុទ្ធ។ ព្រះអង្គហៅពួកសាវ័ក និងពួកហោរាថា ជាអ្នកបរិសុទ្ធពីព្រោះព្រះអង្គញែកលោកទាំងនោះប្រើសម្រាប់កិច្ចការការងារបរិសុទ្ធរបស់ព្រះអង្គ។ ពួកហោរាដែលយើងឃើញក្នុងខនេះជាហោរាក្នុងព្រះគម្ពីរសញ្ញាថ្មី។

"ព្រះវិញ្ញាណ" គឺជាព្រះវិញ្ញាណបរិសុទ្ធ។ តួនាទីរបស់ព្រះអង្គជាអ្នកបង្រៀន

សេចក្តីអាថ៌កំបាំងនៃក្រុមជំនុំ។ ព្រះវិញ្ញាណបរិសុទ្ធជាគ្រូបង្រៀនដល់យើង ជាអ្នកជឿ ដូចព្រះអម្ចាស់យេស៊ូវមានបន្ទូលក្នុងគម្ពីរយ៉ូហាន១៦:១៥ថា "គ្រប់ទាំងអស់ដែលព្រះវរបិតាមាន នោះជារបស់ផងខ្ញុំដែរ ហេតុនោះបានជាខ្ញុំប្រាប់ថា ទ្រង់នឹងយកសេចក្តីដែលជំរូវពីខ្ញុំ មកប្រាប់អ្នករាល់គ្នា"។

តើអ្វីទៅដែលហៅថា អាថ៌កំបាំងក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់? អាថ៌កំបាំងមិនមែនជាហេតុការណ៍ដែលថា សាសន៍ដទៃបានទទួលសេចក្តីសង្គ្រោះក្នុងព្រះគម្ពីរសញ្ញាថ្មីទេ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ព្រះជាម្ចាស់ផ្តល់សេចក្តីសង្គ្រោះដល់សាសន៍ដទៃណា ដែលជឿលើព្រះបន្ទូលរបស់ព្រះអង្គ។ ខ្ញុំសូមជូនខយោងខ្លះស្តីពីដំណើរនេះ។ គម្ពីរអេសាយ១១:១០ចែងថា "នៅគ្រានោះ ឫសនៃអ៊ីសាយនឹងបានតាំងឡើងទុកជាទង់ដល់ជនជាតិទាំងឡាយ ឯគ្រប់សាសន៍ គេនឹងស្វែងរកអ្នកនោះ ឯទីសំរាករបស់អ្នកនោះ នឹងបានជាទីរុងរឿងឧត្តម"។ គម្ពីរអេសាយ៦០:៣ចែងថា "អស់ទាំងសាសន៍នឹងមូលគ្នា មកឯពន្លឺរបស់ឯង ហើយស្តេចទាំងប៉ុន្មាននឹងមកឯរស្មីដែលភ្លឺចេញពីឯង ក្នុងកាលដែលឯងរះឡើង"។ គម្ពីរអេសាយ៤២:៦សម្តែងថា "អញនេះគឺជាយេហូវ៉ា អញបានហៅឯងមកដោយសេចក្តីសុចរិត អញនឹងកាន់ដៃឯង ហើយថែរក្សាឯង អញនឹងតាំងឯងឡើង ទុកជាសេចក្តីសញ្ញាដល់បណ្តាជន ហើយជាពន្លឺភ្លឺដល់អស់ទាំងសាសន៍"។ គម្ពីរសាការី២:១១ចែងថា "នៅគ្រានោះ សាសន៍ជាច្រើននឹងចូលពួកខាងព្រះយេហូវ៉ា គេនឹងបានជារាស្ត្ររបស់អញ ហើយអញនឹងនៅកណ្តាលឯងរាល់គ្នា នោះឯងនឹងដឹងថា ព្រះយេហូវ៉ានៃពួកពលបរិវារ ទ្រង់បានចាត់ឱ្យអញមកឯឯង"។

ឯគម្ពីរម៉ាឡាគី១:១១ចែងដែរថា "ដ្បិតចាប់តាំងពីទិសខាងកើត រហូតដល់ទិសខាងលិច នោះឈ្មោះអញនឹងបានជាធំ នៅកណ្តាលពួកសាសន៍ដទៃ ហើយនៅគ្រប់ទីកន្លែង គេនឹងដុតកំញានថ្វាយដល់ឈ្មោះអញ ព្រមទាំងដង្វាយបរិសុទ្ធផង ដ្បិតឈ្មោះអញនឹងបានជាធំ នៅក្នុងពួកសាសន៍ដទៃវិញ នេះជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ"។

ខ្ញុំចង់អោយលោកអ្នកបងប្អូនកត់ចំណាំអោយបានច្បាស់ អត្ថន័យនៃពាក្យអាថ៌កំបាំងក្នុងព្រះគម្ពីរ។ អាថ៌កំបាំងនោះគឺ "គឺដោយពួកសាសន៍ដទៃបានត្រឡប់ជាអ្នកគ្រងមរតកជាមួយគ្នា និងជារូបកាយជាមួយគ្នា ហើយជាអ្នកទទួលចំណែកនៃសេចក្តីសន្យារបស់ទ្រង់ជាមួយគ្នាក្នុងព្រះគ្រីស្ទដោយសារដំណឹងល្អ"។ នៅក្នុងអាថ៌កំបាំងនេះ សាសន៍ដទៃ និងសាសន៍អ៊ីស្រាអែល មានសិទ្ធិស្មើគ្នា ឥតលើស ឥតខ្វះ។ សាសន៍អ៊ីស្រាអែល ឬសាសន៍ដទៃដែលជឿលើព្រះអម្ចាស់យេស៊ូវជាអង្គសង្គ្រោះ មានឯកសិទ្ធិស្ថិតនៅក្នុងរូបកាយហៅថាក្រុមជំនុំ។ ក្រុមជំនុំជាសាសន៍យូដា និងជាសាសន៍ដទៃមានអង្គព្រះគ្រីស្ទជាសិរសារបស់ខ្លួន។

ទាក់ទងនឹងដំណើរខាងលើ យើងឃើញមានមហាយុគបីធំៗ ដែលព្រះជាម្ចាស់រៀបចំឡើងសម្រាប់សាសន៍យូដា និងសាសន៍ដទៃ។

មហាយុគទីមួយ ចាប់ពីគ្រាលោកតាអ័ដាមមកដល់លោកតាអ័ប្រាហាំ។ មហាយុគនេះមានរយៈពេលជាងពីរពាន់ឆ្នាំ។ ក្នុងមហាយុគនោះ មនុស្សគ្រប់រូបសុទ្ធតែជាសាសន៍ដទៃ។

មហាយុគទីពីរ រាប់ចាប់ពីលោកតាអ័ប្រាហាំ មកទល់នឹងគ្រាព្រះអម្ចាស់

យេស៊ូវគ្រីស្ទយាងមកប្រសូតនៅលើផែនដី។ មហាយុគនេះមានរយៈពេលជាងពីរពាន់ឆ្នាំដែរ។ នៅក្នុងមហាយុគនេះ មនុស្សត្រូវចែកពីរពួក គឺសាសន៍យូដា និងសាសន៍ដទៃ។

មហាយុគទីបី ចាប់ពីថ្ងៃបុណ្យទីហាសិប មកទល់គ្រាមហាសោមនស្ស។ បើយើងចាប់មើលទៅ ប្រមាណជាងពីរពាន់ឆ្នាំ សាសន៍យូដានិងសាសន៍ដទៃ មានឯកសិទ្ធិចូលរួមជារូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទស្មើសិទ្ធិគ្នា។

សាវ័កប៉ុលមានប្រសាសន៍ក្នុងគម្ពីរ១កូរិនថូស១០:៣២ថា "កុំឱ្យធ្វើជាទីបង្អាក់ចិត្ត ដល់ពួកសាសន៍យូដា ឬសាសន៍ក្រេក ឬពួកនៃព្រះឡើយ"។ ខនេះលោកចង់មានប្រសាសន៍ពីមហាយុគទាំងបីដូចរៀបរាប់ខាងលើ។ សាវ័កប៉ុលរាប់បញ្ចូលគ្រួសារមនុស្សលោកគ្រប់ជាតិសាសន៍ ដែលជឿទៅក្នុងរូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺជាក្រុមជំនុំ។

នៅក្នុងព្រះគម្ពីរសញ្ញាចាស់ អ្នកដែលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ មិនមែនជាក្រុមជំនុំទេ។ ក្នុងគម្ពីរម៉ាថាយ១៦:១៨ ព្រះអម្ចាស់យេស៊ូវគ្រីស្ទមានបន្ទូលថា "ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ ហើយទ្វារស្ថានឃុំព្រលឹងមនុស្សស្លាប់នឹងមិនដែលឈ្នះពួកជំនុំឡើយ"។ ចំណុចនេះ ព្រះអង្គមានបន្ទូលពីក្រុមជំនុំដែលត្រូវកើតក្នុងគ្រាអនាគត។ ក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទចាប់កំណើតឡើងនៅថ្ងៃបុណ្យទីហាសិប។ ចាប់ពីថ្ងៃបុណ្យទីហាសិបរៀងមក ក្រុមជំនុំរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ មានរួមទាំងសាសន៍យូដានិងសាសន៍ដទៃ។ ក្រុមជំនុំទាំងពីរសាសន៍នេះ មាននៅលើពិភពលោកយើង ប្រៀបឧបមាដូចជាកូនភ្លោះ។ សាសន៍យូដា

និងសាសន៍ដទៃ ស្ថិតនៅក្នុងរូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ដែលមានព្រះអង្គផ្ទាល់ជាសិរសា។

**ខ្ញុំបានធ្វើជាអ្នកបំរើដំណឹងល្អនោះ តាមព្រះគុណនៃព្រះ ជាអំណោយទានដែលទ្រង់ប្រទានមកខ្ញុំ តាមដែលព្រះចេស្ដាទ្រង់ពូកែនឹងធ្វើ (អេភេសូរ៣:៧)។**

សាវ័កប៉ុលអះអាងជាឱឡារិកថា ថ្វីដ្បិតព្រះជាម្ចាស់តែងតាំងលោកអោយធ្វើជាសាវ័កសម្រាប់សាសន៍ដទៃ លោកមិនមែនជាអ្នកដែលស្គាល់អាថ៌កំបាំងនៃក្រុមជំនុំតែលោកម្នាក់ទេ។ លោកគ្រាន់តែមាននាទីជាបាវបំរើដល់សាសន៍ដទៃតែប៉ុណ្ណោះ។ ឯឯកសិទ្ធិនៃការបម្រើនេះ គឺព្រះជាម្ចាស់ផ្ដល់អោយលោកតាមព្រះគុណដ៏បរិបូររបស់ព្រះអង្គ។ ពីដើមលោកសុលដែលក្រោយមកហៅថា សាវ័កប៉ុល ជាអ្នកបៀតបៀនដល់ក្រុមជំនុំរបស់ព្រះអង្គ។ ឥឡូវនេះ លោកជាសមាជិកមួយរូបនៃក្រុមជំនុំព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបានបំផ្លាស់បំប្រែលោកសុលអោយទៅជាសាវ័កប៉ុល។

**[៨] ទ្រង់បានប្រទានព្រះគុណនេះ គឺជាសម្បត្តិរបស់ព្រះគ្រីស្ទដ៏ប្រមាណមិនបានមកខ្ញុំដែលជាអ្នកតូចជាងបំផុត ក្នុងពួកបរិសុទ្ធ**

**ទាំងអស់ ឱ្យខ្ញុំបានផ្សាយដំណឹងល្អក្នុងពួកសាសន៍ដទៃ ហើយឱ្យខ្ញុំបានបំភ្លឺដល់គ្រប់មនុស្សទាំងអស់ ពីសេចក្តីប្រកបក្នុងការអាថ៌កំបាំង ដែលលាក់ទុកក្នុងព្រះ តាំងពីអស់កល្បរៀងមក ជាព្រះដែលទ្រង់បង្កើតរបស់សព្វសារពើ ដោយសារព្រះយេស៊ូវគ្រីស្ទ (អេភេសូរ៣:៨-៩)។**

បច្ចុប្បន្ននេះ យើងរស់នៅក្នុងបរិយាកាសមួយ ដែលជាកាបើកសម្តែងនៃអាថ៌កំបាំងរបស់ក្រុមជំនុំ។ ឯអាថ៌កំបាំងនោះទៀតសោត គឺយើងរស់ក្នុងព្រះគុណនៃដំណឹងល្អរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ អាថ៌កំបាំងនេះ ពីដើមព្រះជាម្ចាស់មិនទាន់បើកសម្តែងអោយមនុស្សលោកស្គាល់នៅឡើយ។ ទើបតែបច្ចុប្បន្ននេះ ព្រះអង្គបើកសម្តែងអោយយើងស្គាល់ព្រះជាម្ចាស់ថា ទ្រង់ជាអង្គនិម្មាបនិក ទ្រង់បង្កើតគ្រប់សព្វសារពើទាំងឡាយទាំងពួង។ ព្រះជាម្ចាស់មានរឿងច្រើនណាស់ ដែលមិនទាន់អោយយើងដឹងក្នុងសព្វថ្ងៃនេះ។ ខ្ញុំផ្ទាល់ ចេះមិនគ្រប់សព្វទេ។ បើលោកអ្នកយល់ថា ខ្ញុំជាមនុស្សល្ងង់ លោកអ្នកថាត្រូវហើយ។ ពេលខ្ញុំទៅដល់ស្ថានសួគ៌ ទើបខ្ញុំចាប់ផ្តើមរៀនរឿងថ្មីៗទៀតដែលខ្ញុំមិនទាន់បានដឹងនៅឡើយ។ ព្រះជាម្ចាស់មិនបានអោយយើងដឹងអ្វីច្រើនពេកទេ។ ព្រះអង្គបើកសម្តែងល្មមអោយយើងបានទទួលសេចក្តីសង្គ្រោះតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ព្រះអង្គអោយមនុស្សលោករកឃើញធាតុពិតខ្លះៗដែលមាននៅលើលោកនេះដូចជា ពេជ្រ មាស ឬប្រេងកាតជាដើម។ ប៉ុន្តែ បើនិយាយពីការស្គាល់

ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងត្រូវការព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបើកសម្តែងអោយយើងស្គាល់ ទើបយើងអាចស្គាល់ព្រះអង្គបាន។ ក្នុងករណីនេះ ក្រុមជំនុំជាអាថ៌កំបាំង។ យើងមិនអាចស្គាល់ក្រុមជំនុំរបស់ព្រះជាម្ចាស់បាន លើកលែងតែព្រះជាម្ចាស់ត្រាស់ហៅយើងអោយទទួលជឿដល់ព្រះអម្ចាស់ជាអង្គសង្គ្រោះ។

នៅក្នុង៦៨ លោកមានប្រសាសន៍ថា "ខ្ញុំដែលជាអ្នកតូចជាងបំផុត ក្នុងពួកបរិសុទ្ធទាំងអស់"។ សាវ័កប៉ុលច្រើនរាប់ខ្លួនលោកថា ជាអ្នកតូចទាប។ ក្នុងគម្ពីរ១កូរិនថូស១៥:៩ លោកមានប្រសាសន៍ថា "ដ្បិតក្នុងបណ្តាពួកសាវ័ក នោះខ្ញុំជាអ្នកតូចជាងគេ មិនគួរនឹងហៅខ្ញុំជាសាវ័កផងទេ ពីព្រោះខ្ញុំបានបៀតបៀនដល់ពួកជំនុំនៃព្រះ"។ រីឯក្នុងគម្ពីរ១ធីម៉ូថេ១:១២-១៣ លោកមានប្រសាសន៍បន្ថែមទៀតថា "ខ្ញុំអរព្រះគុណដល់ព្រះ ដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ គឺជាព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ពីព្រោះទ្រង់បានរាប់ខ្ញុំទុកជាស្មោះត្រង់ ទាំងតាំងខ្ញុំឱ្យមានការងារ ដែលពីដើមខ្ញុំជាអ្នកប្រមាថ ធ្វើទុក្ខបៀតបៀន ហើយព្រហើនឈ្លានពាន តែទ្រង់បានអាណិតមេត្តាដល់ខ្ញុំ ពីព្រោះខ្ញុំបានប្រព្រឹត្តដោយខ្លៅល្ងង់ ឥតមានសេចក្តីជំនឿ"។

បើតាមជីវិតរបស់លោកសុល ការដែលព្រះជាម្ចាស់រើសលោកយកមកប្រើជាការដែលលោករាប់ថា "...ជាអំណោយទានដែលទ្រង់ប្រទានមកខ្ញុំ តាមដែលព្រះចេស្តាទ្រង់ពូកែនឹងធ្វើ" (៦៧)។

"ហើយឱ្យខ្ញុំបានបំភ្លឺដល់គ្រប់មនុស្សទាំងអស់"។ យើងមិនត្រូវនាំគ្នាប្រកែកប្រណាំងពីអត្ថន័យនៃពាក្យអាថ៌កំបាំងនៃក្រុមជំនុំទេ។ មុខនាទីរបស់យើងដែលជាអ្នក

ជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺយើងត្រូវនាំគ្នាបើកសម្តែងអោយមនុស្សលោកស្គាល់ពីអាថ៌កំបាំងដែលព្រះគ្រីស្ទបានត្រាស់ហៅមនុស្សលោក អោយធ្វើជាក្រុមជំនុំរបស់ព្រះអង្គ។

> **"ដើម្បីឱ្យពួកគ្រប់គ្រង និងពួកមានអំណាចនៅស្ថានដ៏ខ្ពស់ បានស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងណាស់ ដោយសារពួកជំនុំ "តាមគំនិតសំរេចតាំងពីអស់កល្បរៀងមក ដែលទ្រង់បានគិតស្រេចក្នុងព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើង (អេភេសូរ ៣:១០-១១)។**

អាថ៌កំបាំងមួយទៀត ព្រះអង្គចង់អោយមនុស្សលោកស្គាល់ប្រាជ្ញារបស់ទ្រង់តាមរយៈក្រុមជំនុំ។ ក្រុមជំនុំជាភ្នាក់ងារបើកសម្តែងអោយមនុស្សលោកស្គាល់វត្តមានរបស់ព្រះជាម្ចាស់។

> **ហើយក្នុងទ្រង់ យើងរាល់គ្នាក៏មានសេចក្តីក្លាហាន នឹងច្បាប់ចូលដោយទុកចិត្ត ដោយសារសេចក្តីជំនឿជឿដល់ទ្រង់ដែរ (អេភេសូរ ៣:១២)។**

សាសន៍ដទៃមានឯកសិទ្ធចូលទៅដល់ព្រះជាម្ចាស់ តាមរយៈអង្គព្រះយេស៊ូវគ្រីស្ទ។

**ហេតុនោះបានជាខ្ញុំសូមអង្វរអ្នករាល់គ្នា កុំឱ្យរសាយចិត្តដោយការដែលខ្ញុំរងទុក្ខលំបាក ជាការដែលមានប្រយោជន៍ដល់អ្នករាល់គ្នានោះឡើយ ដ្បិតការនោះជាសិរីល្អដល់អ្នករាល់គ្នាទេ (អេភេសូរ ៣:១៣)។**

សាវ័កប៉ុលលើកទឹកចិត្តដល់ពួកជំនុំនៅទីក្រុងអេភេសូរថា "ហេតុនោះបានជាខ្ញុំសូមអង្វរអ្នករាល់គ្នា កុំឱ្យរសាយចិត្តដោយការដែលខ្ញុំរងទុក្ខលំបាក ជាការដែលមានប្រយោជន៍ដល់អ្នករាល់គ្នានោះឡើយ ដ្បិតការនោះជាសិរីល្អដល់អ្នករាល់គ្នាទេ"។ សាវ័កប៉ុលមានប្រសាសន៍រួចមកហើយ ពីឯកសិទ្ធិដែលសាសន៍ដទៃបានទទួលដោយសារដំណឹងល្អនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ លោកមិនចង់អោយពួកជំនុំសាសន៍ដទៃនៅទីក្រុងអេភេសូរមានការអស់ទឹកចិត្ត ដោយសារឃើញលោកជាប់ក្នុងមន្ទីរឃុំឃាំងនោះទេ។ ការជាប់មន្ទីរឃុំឃាំង ដែលលោកកំពុងឆ្លងកាត់ពេលនេះ ជាសិរីល្អសម្រាប់សាសន៍ដទៃ។ លោកមានប្រសាសន៍ក្នុងគម្ពីរកូល៉ុស១:២៤ថា "ឥឡូវនេះ ខ្ញុំមានចិត្តអំណរក្នុងការរងទុក្ខលំបាក ដែលខ្ញុំទ្រាំដោយព្រោះអ្នករាល់គ្នា ហើយសេចក្ដីវេទនាណារបស់ព្រះគ្រីស្ទ ដែលខ្វះក្នុងរូបសាច់ខ្ញុំ នោះខ្ញុំកំពុងតែបំពេញឡើង ដោយព្រោះរូប

កាយទ្រង់ គឺជាពួកជំនុំ”។

យើងស្លេះការសិក្សាគម្ពីរអេភេសូរត្រឹមណោះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ “ដើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!”